**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ធំ**

- សាលក្រមលេខៈ ៥៨ "ន"
  ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣
- សំណុំរឿងព្រហ្មទណ្ឌលេខៈ៣៧៨
  ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២
- សំណុំរឿងស៊ើបសួរលេខៈ២៧៧
  ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២
- សំណុំរឿងជំនុំជម្រះលេខៈ៥៥
  ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពង់ធំ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកំពង់ធំ នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣
វេលាម៉ោង០៨ និង០០នាទីព្រឹក ដែលមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក[redacted] ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តកំពង់ធំ

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ធំ

**ក្រឡាបញ្ជីសវនាការ**

លោក[redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ធំ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ៣៧៨ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ដែលមាន៖

<u>**ជនជាប់ចោទ៖**</u>

១-ឈ្មោះ[redacted] ភេទស្រី អាយុ ៥៣ឆ្នាំ ជនជាតិដើមភាគតិចគួយ សាសនាព្រះពុទ្ធ មុខរបរធ្វើការ កម្រិតវប្បធម៌៖ថ្នាក់ទី៤ ទីកន្លែងកំណើតនៅភូមិឯន ឃុំឯន ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ននៅភូមិឯន ឃុំឯន ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។ ឪពុកឈ្មោះ[redacted] "ស" ម្ដាយឈ្មោះ[redacted] "រ" ប្ដីឈ្មោះ[redacted] មានកូន០៥នាក់។ ទោសពីមុនគ្មាន។

-បានចូលមកបង្ហាញខ្លួននៅចំពោះមុខតំណាងអយ្យការ និងចៅក្រមស៊ើបសួរ។

-ដីកាបង្គាប់ឲ្យដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំបណ្ដោះអាសន្នលេខ៖៧២ ត.ព្រ-២០២២ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ។

២-ឈ្មោះ [redacted] ភេទស្រី អាយុ ២៤ឆ្នាំ ជនជាតិដើមភាគតិចគួយ មុខរបរធ្វើចំការ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌៖ថ្នាក់ទី៧ ទីកន្លែងកំណើតនៅភូមិឯន ឃុំឯន ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ន

នៅភូមិឯន ឃុំឯន ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។ ឪពុកឈ្មោះ[redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ប្ដី ឈ្មោះ[redacted] មានកូន០២នាក់។ ទោសពីមុនគ្មាន។

-បានចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។

-ដីកាសម្រេចមិនឃុំបណ្ដោះអាសន្នលេខ៖៣២៤/២០២២ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ។

ត្រូវបានជាប់ចោទពីបទៈ **ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណុចតំបន់ក្បិតបង្គួរខ្នា ភូមិឯន ឃុំឯន ស្រុកសណ្ដាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ តាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]**

មេធាវី[redacted] អត្តលេខៈ២១០២ មានការិយាល័យផ្ទះលេខ១៧៤ ផ្លូវសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] និងឈ្មោះ[redacted]**

មេធាវី[redacted] អត្តលេខៈ៥៦៤ មានការិយាល័យនៅអង្គការលីកាដូ ផ្ទះលេខ១៦ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

មេធាវី[redacted] អត្តលេខៈ៥៦៩ មានការិយាល័យនៅអង្គការលីកាដូ ផ្ទះលេខ១៦ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

មេធាវី[redacted] អត្តលេខៈ៨១៧ មានការិយាល័យនៅផ្ទះលេខ២៨ ផ្លូវលេខ៤៦០ សង្កាត់ទួលទំពូង ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ដើមបណ្ដឹងរដ្ឋប្បវេណី**

ឈ្មោះ[redacted] ភេទប្រុស អាយុ ៦១ឆ្នាំ ជាតិខ្មែរ មុខរបរប្រធានគ្រប់គ្រងក្រុមហ៊ុនសម្បត្តិ ផ្ដេធីណឹម ខូអិលធីឌី ទីកន្លែងកំណើតភូមិរាំងខាងត្បូង ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ននៅភូមិថ្មី ឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។ ឪពុកឈ្មោះ[redacted] "ស" ម្ដាយឈ្មោះ[redacted] "ស" ប្រពន្ធឈ្មោះ[redacted]"រ" មានកូន០៤នាក់។

**មេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី**

មេធាវី[redacted] អត្តលេខ៖៨៧២ មានការិយាល័យនៅផ្ទះលេខ២៦អាអ៊ី០ ផ្លូវលេខ៖២១៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## ១. អង្គហេតុដែលប្ដឹងមកតុលាការមានដូចតទៅ

យោងតាមដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ បញ្ជាក់ថា៖ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង១៣ និង០០នាទី នៅចំណុចតំបន់ក្បិតបង្គួរខ្នា ភូមិឯន ឃុំឯន ស្រុកសណ្ដាន់ ខេត្តកំពង់ធំ មានករណី ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត កើតឡើង ដែលបង្កដោយជនជាប់ចោទឈ្មោះ[redacted] ភេទស្រី អាយុ ៥៣ឆ្នាំ និងជនជាប់ចោទឈ្មោះ[redacted] ភេទស្រី អាយុ ២៤ឆ្នាំ ដែលបានធ្វើការឈូសឆាយដីរបស់ក្រុមហ៊ុន សម្បត្តិ ផ្ដេធីណឹម ខូអិលធីឌី អស់ទំហំ២១ហិចតា លុះពេលសមត្ថកិច្ចចុះទៅដល់ចំណុចកើតហេតុ ឃើញតែត្រាក់ទ័រនៅក្នុងដីរបស់ក្រុមហ៊ុន ដោយអ្នកបើកបរបានបើកត្រាក់ទ័ររត់គេចខ្លួនបាត់ ក្រោយពេលធ្វើការស្រាវជ្រាវឃើញថា ជនជាប់ចោទឈ្មោះ[redacted] និងជនជាប់ចោទឈ្មោះ[redacted]ជាម្ចាស់ត្រាក់ទ័រ ទើបឈ្មោះ[redacted] ដែលជាអ្នកគ្រប់គ្រងទូទៅនៅក្នុងក្រុមហ៊ុនខាងលើបានដាក់ពាក្យបណ្ដឹងប្ដឹងជនជាប់ចោទខាងលើតែម្ដង។

១០/៤

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖៦៤៧/២០២២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ធំ។

-បានឃើញ ដីកាដំណោះស្រាយលេខ៖១១៥/២០២៣ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ៖៥៦ គ.ព្រ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកំពង់ធំ។

## ២. ពេលសវនាការ

<u>សវនាការលើកទី១ (ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង៨ព្រឹក)</u>

- ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនមិនបានឈូសឆាយដីរបស់ក្រុមហ៊ុននោះទេ ព្រោះដីនោះជាដីរបស់ឈ្មោះ [redacted] ទេ។ ខ្លួនបានឈូសឆាយនៅលើដីចម្ការចន្ទីររបស់ឈ្មោះ [redacted] ដោយសារខ្លួនបានដីនោះពីឈ្មោះ [redacted] តែគាត់មិនមានឯកសារណាបញ្ជាក់ថា គាត់បានដីនោះមកពីណានោះទេ។ ខ្លួនបានឈូសឆាយក្នុងគោលបំណង ដើម្បីដាំដំឡូងទេ ហើយព្រៃដែលឈូសនោះ គឺមិនមានព្រៃធំដុំនោះទេ។ នៅថ្ងៃកើតហេតុ ពេលគេឈូស ខ្លួនមិនបាននៅកន្លែងកើតហេតុរហូតនោះទេ ហើយនៅពេលគេចាប់ត្រាក់ទ័រហើយ ទើបខ្លួនទៅដល់ទីកន្លែងកើតហេតុ។ ថ្ងៃដែលខ្លួនចូលទៅឈូសដីនោះ គឺមានគេប្ដឹងតែម្ដង។ ពេលចូលឈូសឆាយ ខ្លួនមិនបានជូនដំណឹងទៅណានោះទេ ដោយសារដីនោះមានដាំដំណាំហើយដូចជា ដើមចន្ទីរអាយុជិត១០ឆ្នាំហើយ។ ឈ្មោះ [redacted] ត្រូវបងប្អូនជីដូនមួយ ហើយដីដែលឈូសឆាយនោះ ជាដីរបស់ឈ្មោះ [redacted] ក។ ពេលដែលខ្លួនឈូសដីនោះ គឺមានទំហំ១ហិចតា៣៤អា ដោយទើបតែឈូសបាន១ថ្ងៃជាងទេ ក៏មានការមកឃាត់ត្រាក់ទ័រ ហើយឈូសបានតែប៉ុននេះទេ។ កាលពីឆ្នាំ២០១២ ដីនោះគឺជាដីរបស់ក្រុមហ៊ុនមែន ក្រោយមកអាជ្ញាធរបានចេញឯកសារកាត់ឆ្វៀលដីនោះឱ្យមកខ្លួន។ នៅពេលដែលបែងចែកឆ្វៀលដីនោះ គឺមានភាគីខាងក្រុមហ៊ុនចូលរួមដែរ។ ដីនោះគឺមានទំហំ ១ហិចតា៣៤។ ខ្លួនមិនដែលមានទំនាស់ជាមួយភាគីខាងក្រុមហ៊ុននោះទេ។ ដីនេះខ្លួនរស់នៅតាំងពីមុនក្រុមហ៊ុនចូលមកកាន់កាប់ទៀត តែមិនដឹងថាមានទំហំប៉ុន្មានហិចតានោះទេ ដោយខ្លួនស្គាល់តែព្រំប្រទល់ដីរបស់ខ្លួនទេ។ ក្រុមហ៊ុនចូលមកកាន់កាប់ដីនោះនៅក្នុងឆ្នាំ២០១២ ហើយភាគីខាងក្រុមហ៊ុនក៏បានធ្វើប្លង់នៅលើដីរបស់ខ្លួននោះ។ ចំពោះ ដីដែលក្រុមហ៊ុនបានឈូសឆាយហើយ គឺមិនបានកាត់មកឱ្យប្រជាពលរដ្ឋនោះទេ។ កន្លងមក ខ្លួនបានដាក់ពាក្យសុំដីនោះមកខាងសាលាខេត្ត តាំងពីឆ្នាំ២០១៤ មក ហើយខាងអាជ្ញាធរឃុំក៏បានធ្វើលិខិតបញ្ជាក់ថា ដីនោះពិតជាដីរបស់ខ្លួនមែន។ ឈ្មោះ [redacted] បានអាស្រ័យផលនៅលើដីនោះបន្តពីម្ដាយរបស់គាត់មក។ ចម្ងាយពីដីរបស់ឈ្មោះ [redacted] ទៅក្រុមហ៊ុន គឺមានចម្ងាយប្រហែល៣០០ម៉ែត្រ។ ក្រោយមានទំនាស់ អាជ្ញាធរមិនបានហាមឃាត់ទេ គឺមានតែក្រុមហ៊ុនទេ។ ចំពោះ ត្រាក់ទ័រ គឺគេផ្សេងជាអ្នកបើកទេ ដែលមានឈ្មោះ [redacted] ហើយនៅពេលគេឃាត់ត្រាក់ទ័រ វាក៏រត់បាត់ទៅ ហើយមិនមានការកាប់ដោយកាំបិតនោះទេ។ ចំពោះ ត្រាក់ទ័រនោះជារបស់កូនខ្លួន គឺខាងសមត្ថកិច្ចបានប្រគល់ឱ្យវិញហើយ ដោយបានបង់ប្រាក់ឱ្យស្នងការរងឈ្មោះ [redacted] ចំនួន១៦លានរៀល។ វិវាទដីនេះ ខ្លួនបានចូលទៅដោះស្រាយម្ដងរួចហើយ តែមិនទាន់មានដំណោះស្រាយនោះទេ ដោយមានតែការដាក់បន្ទុកមកលើខាងសហគមន៍។ ក្នុងឃុំឯន មិនទាន់មានការធ្វើប្លង់ជាប្រព័ន្ធទេ។ ដីនៅទីនោះ គឺប្រើប្រាស់ប្លង់រួមរបស់សហគមន៍ ហើយខាងខេត្តក៏ធ្លាប់ចុះទៅវាស់ឱ្យហើយដែរ តែមិនទាន់ចេញប្លង់រឹងឱ្យនៅឡើយទេ។ ខ្លួនមិនដែលឃើញក្រុមហ៊ុនបង្ហាញប័ណ្ណកម្មសិទ្ធិលើដីនោះឱ្យខ្លួនមើលទេ។ សហគមន៍ម៉ាឡុនសមាជិក៤២២នាក់ ខ្លួនជាអនុប្រធានទី២ នៃគណៈកម្មការសហគមន៍ ដោយបានចុះបញ្ជីនៅក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងមហាផ្ទៃ។ ខ្លួនចង់តទល់ជាមួយដើមបណ្ដឹង តែគាត់មិនបានមកចូលរួមសវនការនាពេលនេះទេ។

- ជនជាប់ចោទឈ្មោះ[redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនត្រូវជាកូនរបស់ឈ្មោះ[redacted]។ មកដល់បច្ចុប្បន្ននេះ ដីនោះបានប្រគល់ឱ្យទៅឈ្មោះ[redacted] វិញហើយ។ ខ្លួនបានឈូសឆាយលើដីនោះបានតែទំហំ ១ហិចតា៣៤អា ទេ។ ខ្លួនមិនដែលបានជជែកដោះស្រាយជាមួយក្រុមហ៊ុននោះទេ។ កាលពីថ្ងៃកើតហេតុខ្លួននៅផ្ទះ ហើយពីផ្ទះខ្លួនទៅកន្លែងកើតហេតុ គឺមិនឆ្ងាយនោះទេ។ ត្រាក់ទ័រជារបស់ខ្លួន ហើយអ្នកបើកជាប្អូនជីដូនមួយខ្លួន។ ពេលទៅដល់កន្លែងកើតហេតុ ម៉ោងប្រហែល២រសៀល ប៉ុន្តែ នៅពេលកើតហេតុ គឺមិនដឹងថាម៉ោងប៉ុន្មាននោះទេ។ ចំពោះ ត្រាក់ទ័រនោះ គឺទិញយកមកដើម្បីឱ្យគេជួល ហើយអ្នកបើកជាកម្មករខ្លួន ដែលខ្លួនជួលឱ្យឈូសដីនោះ។ ចម្ងាយពីដីក្រុមហ៊ុនទៅដីឈ្មោះ[redacted] គឺចម្ងាយប្រហែល៣០០ម៉ែត្រ។

- សាក្សីឈ្មោះ[redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនបានស្គាល់គាត់ទាំងពីរនាក់នេះ ដោយពួកគាត់ជាបងប្អូនជីដូនមួយខ្លួន។ កាលពីដើមឡើយ ម្តាយក្មេកខ្លួនគាត់បានឱ្យដីនោះមកខ្លួន ដោយមានដាំស្វាយចន្ទីរប្រហែល១០ឆ្នាំហើយ ដោយដាំតាំងពីមុនក្រុមហ៊ុនចូលមកកាន់កាប់ទៀត។ ដីនោះមានជាប់ព្រំប្រទល់ជាមួយដីក្រុមហ៊ុន រហូតឆ្នាំ២០១៤ ទើបមានការបែងចែកព្រំប្រទល់គ្នា។ កន្លងមក មិនមានប្រជាពលរដ្ឋណាចូលទៅឈូសឆាយដីនោះទេ ហើយសព្វថ្ងៃ ខ្លួនមិនដឹងថាក្រុមហ៊ុននៅកាន់កាប់ដីនោះបន្ត ឬអត់នោះទេ។ ដីនោះមិនមានលិខិតស្នាមអ្វីនោះទេ។ ដីដែលដាំដំឡូងនោះ គឺដីដែលខ្លួនអនុញ្ញាតឱ្យគាត់ទាំងពីរនាក់ចូលទៅឈូសឆាយមែន មិនមែនជាដីក្រុមហ៊ុននោះទេ។ ខ្លួនមិនបានដឹងថា តាកុងត្រាក់ទ័របានទៅឈូសឆាយលើសពីដីខ្លួនមាន ឬអត់នោះទេ។ ក្នុងរូបដែលតំណាងអយ្យការបង្ហាញ ដីក្នុងរូបមួយនោះជារបស់ខ្លួន ហើយមួយទៀតគឺមិនមែនទេ។

- តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ចម្លើយសាក្សី និងពិនិត្យភស្តុតាងនានា ឃើញថា សំណើរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ គឺចង់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានវត្តមាននាពេលសវនការនេះ គឺអាចទទួលយកបាន។ ដូច្នេះ តំណាងអយ្យការស្នើសុំលើកសវនាការទៅពេលក្រោយទៀត ដើម្បីរង់ចាំមានវត្តមានដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីស្វែងរកការពិត។

- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] មេធាវី[redacted] ធ្វើសេចក្តីសន្និដ្ឋានការពារ៖ ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបានអវត្តមាន និងមានសាក្សីបន្ថែមទៀត។ ដូច្នេះ សំណូមពរឱ្យមានដេញដោលបន្តនៅលើកក្រោយទៀត។

- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] និងឈ្មោះ[redacted] មេធាវី[redacted] ធ្វើសេចក្តីសន្និដ្ឋានការពារ៖ ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបានអវត្តមាន និងមានការស្នើសុំបញ្ចូលសាក្សីបន្ថែមទៀត។ ដូច្នេះ ស្នើសុំដេញដោលនៅពេលក្រោយទៀត ដោយឱ្យមានវត្តមានដើមបណ្តឹងរដ្ឋប្បវេណីចូលរួម។

- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] និងឈ្មោះ[redacted] មេធាវី[redacted] ធ្វើសេចក្តីសន្និដ្ឋានការពារ៖ ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបានអវត្តមាន។ ដូច្នេះ ស្នើសុំដេញដោលនៅពេលក្រោយទៀត ដោយឱ្យមានវត្តមានដើមបណ្តឹងរដ្ឋប្បវេណីចូលរួម ដើម្បីឱ្យមានការតទល់គ្នាស្វែងរកការពិត។

<u>សវនាការលើកទី២ (ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង២រសៀល)</u>

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនជាតំណាងរបស់ក្រុមហ៊ុន មានលិខិតផ្ទេរសិទ្ធិពីក្រុមហ៊ុន ហើយក្រុមហ៊ុនប្តឹងពួកគាត់ ដោយសារពួកគាត់យកត្រាក់ទ័រមកឈូសឆាយលើដីរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនបានជួលដីនោះពីរដ្ឋរយៈពេល ៣០ឆ្នាំ។ មូលហេតុដែលខ្លួនដឹង ដោយសារមានកម្មកររត់មកប្រាប់ ហើយខ្លួនបានទៅមើលឃើញដែរ។ ដីដែលពួកគាត់បានឈូសឆាយនោះគឺមានទំហំ២២ហិចតា ចូលឈូស

បានប្រហែល៣០ផង ពីពេលព្រឹកដល់ល្ងាច រយៈពេលប្រហែល១ខែជាង ដោយគាត់ឈូសឆាយបន្តិចម្ដងៗ។ គាត់ឈូសឆាយចូលក្នុងដីរបស់ក្រុមហ៊ុនប្រហែលកន្លះគីឡូម៉ែត្រ។ ខ្លួនមិនដឹងមូលហេតុដែលគេឈូសឆាយនោះទេ។ ខ្លួនជាមួយប៉ូលិសសេដ្ឋកិច្ចបានចុះទៅហាមឃាត់ពួកគាត់ ដោយបានឃាត់ទាំងមនុស្ស និងត្រាក់ទ័រ។ មុននឹងប្ដឹង ខ្លួនបានទៅមើលឃើញជាក់ស្ដែងហើយ គឺមានត្រាក់ទ័រគាត់នៅដីនោះមែន វេលាម៉ោងប្រហែល៣រសៀល មិនចាំថ្ងៃខែនោះទេ ដោយឃើញប្ដីរបស់ឈ្មោះ[redacted] កំពុងបើកត្រាក់ទ័រឈូសឆាយ។ អ្នកដែលចូលទៅឈូសឆាយ គឺមានឈ្មោះ[redacted] ដោយខ្លួនបានឃើញគាត់ចូលទៅដីនោះ និងឃើញប្ដីរបស់ឈ្មោះ[redacted] ចូលទៅ។ កូនប្រសាររបស់ឈ្មោះ[redacted] ត្រូវជាប្ដីរបស់ឈ្មោះ[redacted] ជាអ្នកចូលទៅឈូសឆាយ ដោយខ្លួនមិនស្គាល់ឈ្មោះទេ។ មូលហេតុដែលគាត់អាចឈូសបាន ដោយសារគាត់បានដាក់គ្នាគាត់នៅលើដើមឈើចាំមើល បើឃើញខាងយើងចុះទៅ គាត់រត់បាត់ហើយ ដោយមិនបានឃើញជនជាប់ចោទទាំងពីរនាក់នេះនៅកន្លែងកើតហេតុនោះទេ។ កន្លងមក មានតែក្រុមពួកគាត់ទេដែលចូលទៅក្នុងដីរបស់ក្រុមហ៊ុននោះ ដោយមិនមានអ្នកណាហ៊ានចូលទៅទេ ហើយមានតែត្រាក់ទ័រគាត់មួយទេឃើញចូលឈូសឆាយលើដីនោះរហូត។ កន្លងមក ខាងខ្លួនមិនដែលបានហៅគាត់មកធ្វើកំណត់ហេតុអីនោះទេ។ កន្លងមក ខ្លួនបានប្រាប់ណែនាំគាត់ដែរ តែមិនបានប្រាប់ដោយផ្ទាល់នោះទេ។ ចំពោះ សំណុំរឿងនេះគឺមានតែប្ដឹងមកតុលាការទេ មិនដែលបានប្ដឹងទៅភូមិឃុំនោះទេ។ ដីនោះគឺមានព្រៃដែរ។ ចំពោះ ការកំណត់ព្រំប្រទល់ដី គឺក្រុមហ៊ុនបានបោះបង្គោលព្រំក្នុងចម្ងាយដីមួយគីឡូម៉ែត្រ មានបង្គោលមួយ។ ខ្លួនស្គាល់ឈ្មោះ[redacted] តែខ្លួនមិនដឹងថា គាត់មានដីនៅជាប់ព្រំប្រទល់ ឬអត់នោះទេ ហើយខ្លួនមិនដឹងថាដីអ្នកណានៅជាប់ព្រំនោះទេ។

-មេឃុំឯន ឈ្មោះ[redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនបានដឹងពីទំហំដីដែលឈ្មោះ[redacted] និងឈ្មោះ[redacted] ចូលទៅភ្ជួរដីនោះ ដោយទំហំឈូសឆាយគឺ ១ហិចតា១២អា។ ខ្លួនមិនដឹងថា ដីនោះក្រុមហ៊ុនបានសម្បទានពីឆ្នាំណានោះទេ។ ថ្ងៃដែលខាងខ្លួនចុះទៅមើលនោះ គឺថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២។ ខ្លួនមិនដឹងថា ដីនោះឈ្មោះ[redacted] និងឈ្មោះ[redacted] បានមកពីណានោះទេ។ កន្លងមក ខ្លួនមិនដែលបានទទួលពត៌មានពីការឈូសឆាយនោះទេ។ ចំណុចដែលឈូសឆាយដីនោះ គឺមាននៅក្នុងផែនទីរបស់ក្រុមហ៊ុនមែន តែចំណុចឈូសនោះ គឺប្រជាជនអាស្រ័យផលតាំងពីយូរមកហើយ មុនក្រុមហ៊ុនមកសម្បទានដីនេះទៀត។ ខ្លួនបានឡើងធ្វើមេឃុំនេះ តាំងពីឆ្នាំ២០១៧។ ឈ្មោះ[redacted] និងឈ្មោះ[redacted] ចូលកាន់កាប់អាស្រ័យផលលើដីនោះតាំងពីឆ្នាំ២០១៤។ ចំពោះ ខាងសហគមន៍ធ្លាប់ស្នើសុំធ្វើប្លង់ដីនោះដែរ តែមិនមានឯកសារផ្លូវការនោះទេ។ កន្លងមក ក៏ធ្លាប់មានការចុះទៅវាស់វែងដីនោះដែរ។ កន្លងមក មិនដែលមានការដោះស្រាយជាមួយក្រុមហ៊ុននោះទេ។ ក្រៅពីដីសម្បទាននោះ គឺមិនមានដីទំនេរសម្រាប់ប្រជាជនអាស្រ័យផលនោះទេ។ ខ្លួនមិនបានឃើញការធ្វើសកម្មភាពឈូសឆាយដីនោះដោយផ្ទាល់នោះទេ គ្រាន់តែឃើញដីក្រោយពេលធ្វើការឈូសឆាយហើយទេ។ កន្លងមក ធ្លាប់មានការស្នើសុំពីភាគីជនជាប់ចោទ ដើម្បីដោះស្រាយជាមួយខាងក្រុមហ៊ុនដែរ។ ខ្លួនមិនដឹងថា ស.ជ.ណ ដែលកាត់ដីសម្បទានឱ្យក្រុមហ៊ុននោះមានដីទំហំប៉ុណ្ណានោះទេ។ ចំពោះ ដីនោះគឺគាត់តែងតែធ្វើជាពនេចរ វិលជុំរហូត។ អាជ្ញាធរយើងក៏ធ្លាប់ជូនដំណឹងដែរ តែប្រជាជនគាត់មិនបានយល់នោះទេ។ ចំពោះ ទីតាំងប្រឡាយដែលគិតថាជាព្រំប្រទល់នោះ គឺនៅក្នុងផែនទី ជាដីរបស់ក្រុមហ៊ុនទេ។ ដីដែលចុះទៅឈូសឆាយនោះ ជាដីរបស់ឈ្មោះ[redacted]។ ពេលដែលខ្លួនចុះទៅជាក់ស្ដែង គឺឃើញមានដាំដើមចន្ទីរ មិនមានព្រៃឈើអ្វីនោះទេ។ ដីនោះឈ្មោះ[redacted] បានកាន់កាប់យូរមកហើយ គឺមានលិខិតបញ្ជាក់មែន តែគ្រាន់តែបញ្ជាក់ថា កាន់កាប់បណ្ដោះអាសន្នទេ។ បើតាមផែនទីរដ្ឋបាលគឺដីនោះ គឺនៅក្នុង *ភូមិមានជ័យ* ទេ។

-មេភូមិជ័ន លោក[redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនជាមេភូមិឯន តាំងពីឆ្នាំ២០០៦ មក។ ខ្លួនស្គាល់ភាគីទាំងសងខាង ដោយមិនមានត្រូវជាសាច់ញាតិខាងណាមួយនោះទេ។ ខ្លួនមិនដឹងថា គេឃាត់ឈ្មោះ ឡាយភាគ និង

ឈ្មោះ [redacted] នោះទេ។ ខ្លួនស្គាល់ទីតាំងដីនោះ។ ចំពោះ ទីតាំងដីនោះ និងដីក្រុមហ៊ុន គឺនៅផ្សេងគ្នាទេ
ប៉ុន្តែ ខ្លួនមិនបានផ្ទៀងផ្ទាត់ជាមួយផែនទីរបស់ក្រុមហ៊ុននោះទេ។ ទំហំដីដែលឈ្លូសឆាយនោះ គឺមានទំហំ ១ហិចតា
១២អា ដោយប្ដីរបស់ឈ្មោះ [redacted] ជាអ្នកចូលទៅឈ្លូសឆាយ។ ឈ្មោះ [redacted] មិនបានទៅដីនោះទេ។
ពេលចុះទៅវាស់វែងនោះ គឺមានដើមចន្ទីរ។ ពេលដែលខ្លួនចុះទៅវាស់វែងនោះ មិនបានចុះទៅជាមួយភាគីខាងក្រុម
ហ៊ុននោះទេ។ ពេលវាស់ទៅ ឃើញថា ទំហំដីដែលឈ្លូសឆាយគឺ ១ហិចតា១២អា។ ដើមចន្ទីរនោះជារបស់ឈ្មោះ
[redacted]។ ដីដែលឈ្លូសឆាយនោះគឺនៅខាងក្រៅប្រឡាយដែលគេកាយនោះទេ។ ដីទំនាស់នោះជារបស់ឈ្មោះ
[redacted]។ ខ្លួនមិនដឹងថា អ្នកទាំងពីរនាក់នោះ គាត់បានដីនោះមកពីឈ្មោះ [redacted] តាមវិធីណាទេ។ ខ្លួន
មិនបានដឹងថា ព្រំប្រទល់ក្រុមហ៊ុននៅត្រឹមណានោះទេ។ ចំពោះ លិខិតដែលខ្លួនបញ្ជាក់នោះ ខ្លួនទទួលស្គាល់ ហើយ
ខ្លួនគ្រាន់តែបានបញ្ជាក់ថា ទំហំដីដែលឈ្លូសឆាយនោះទេ តែមិនបានបញ្ជាក់ថា ដីនោះនៅភូមិឃុំណាទេ។

- ស្មៀនឃុំងន លោក [redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនបានធ្វើស្មៀនឃុំ តាំងពីឆ្នាំ២០១៧ មក។ ខ្លួនមិន
បានដឹងរឿងនេះទេ។ ខ្លួនគ្រាន់តែបានចូលរួមកត់កំណត់ហេតុ វាស់វែង និងបានឃើញដីខូចខាតនោះគឺប្រហែល១
ហិចតាជាង។ ខ្លួនមិនដឹងថា ដីនោះនៅក្នុងដីក្រុមហ៊ុន ឬអត់នោះទេ។ ខ្លួនមិនបានចុះទៅជាមួយតំណាងក្រុមហ៊ុន
នោះទេ។ តាំងពីដើមមក ខ្លួនមិនដឹងប្រវត្តិដីនោះទេ។ នៅពេលវាស់វែង ឈ្មោះ [redacted] ក៏បានចូលវាស់វែងដែរ។

- សាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនស្គាល់ឈ្មោះ [redacted] និងឈ្មោះ [redacted]
ទាំងពីរនាក់នេះ ដោយគាត់ជាអ្នកជិតខាង។ ដីរបស់គាត់ជាប់ព្រំប្រទល់នឹងដីខ្លួន។ ខ្លួនមិនដឹងថា ដីខ្លួនមានប៉ុន្មាន
ហិចតានោះទេ។ ដីខ្លួនខាងកើតជាប់នឹងដីឈ្មោះ [redacted] តែមិនមានលិខិតស្នាមអីនោះទេ។ ដីខ្លួនធ្លាប់មាន
ទំនាស់ជាមួយក្រុមហ៊ុនដែរ តែមិនចាំឆ្នាំទេ។ ខ្លួនបានឈប់ចូលទៅធ្វើលើដីនោះទៀតហើយ ដោយធ្វើនៅក្រៅដី
របស់ក្រុមហ៊ុន។ ខ្លួនបានឲ្យដីទៅឈ្មោះ [redacted] និងឈ្មោះ [redacted] អាស្រ័យផលដែរ តែគាត់មិនឈ្លូស
ចូលដីខ្លួនទេ។

- សាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ ឈ្មោះ [redacted] ជាម្ដាយមីងខ្លួន។ ដីដែលគាត់ឈ្លូស
ឆាយនោះគឺនៅក្រៅដីរបស់ក្រុមហ៊ុនទេ ដោយសារឈ្លូសនៅក្រៅប្រឡាយ ជាដីប្រជាជនបានអាស្រ័យផលធម្មតា
ដីស្វាយចន្ទីរ។ ខ្លួនមិនមានដីនៅតំបន់នោះទេ។ ដីរបស់មីងឈ្មោះ [redacted] គឺឈ្លូសឆាយ ដើម្បីដាំដំឡូង។ ដី
របស់ឈ្មោះ [redacted] និងដីរបស់គាត់ គឺជាប់គ្នា។ ដីនោះជាដីប្រជាជនអាស្រ័យផលយូរហើយ។ ខ្លួនមិនបាន
ចុះទៅមើលដីនោះជាក់ស្ដែងទេ។ ដីនោះជាដីខាងសហគមន៍។

- សាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនជាជំនួយការរបស់ក្រុមហ៊ុន។ ពេលគេចាប់ដី ខ្លួនបានចុះ
ទៅមើល ហើយធ្វើការចុចជីភីអេស ឃើញថា ពួកគាត់បានឈ្លូសចូលដីរបស់ក្រុមហ៊ុន ដោយចូលដីក្រុមហ៊ុន
ប្រហែល១ហិចតាជាង។ ជាគោលការណ៍ ការកំណត់ព្រំ គឺគេយកបង្គោលធ្វើព្រំ ហើយការកាយប្រឡាយ គឺមិន
មែនកំណត់ព្រំទេ។ ដីនោះគឺនៅចាំការដោះស្រាយសិន តែប្រជាជនចេះតែចូលមកអាស្រ័យផលរហូត។ កន្លងមក
ដីនោះមិនធ្លាប់មានការដោះស្រាយជាមួយគាត់ទាំងពីរនាក់នោះទេ ដោយសារពេលក្រុមហ៊ុនទៅ គឺពួកគាត់រត់រហូត។
ពេលទៅចាប់ ខ្លួនឃើញមានត្រាក់ទ័រពីរគ្រឿង។ អ្នកចុចជីភីអេសចេះចុចច្បាស់ ដោយរៀននៅសាលា CUS។ ដី
ដែលឈ្លូស គឺដីព្រៃ មិនមានដើមចន្ទីរទេ។ ក្នុងដីក្រុមហ៊ុន គឺមានចន្ទីរដែរ តែចំណុចដែលឈ្លូសនោះ គឺមិនមានចន្ទីរ
ទេ។ ដីវិវាទនោះ គឺនៅភូមិមានជ័យទេ មិនមែនភូមិងនទេ ផ្អែកតាមជីភីអេស។ តែប្រជាជននៅភូមិងនចូលមក
អាស្រ័យផល ដោយសារជាភូមិជិតជាង។ គាត់ធ្វើសកម្មភាពអាស្រ័យផលដីចោះ១នៅក្នុងដី២២ហិចតា ហើយ១
ហិចតាជាងនោះ គ្រាន់តែជាចំណុចមួយទេ នៅកន្លែងផ្សេងទៀត។ មូលហេតុដែលដូរភូមិ ដោយសារគាត់នៅក្នុង
ភូមិងន តែកើតហេតុនៅភូមិមានជ័យ។ ដីនោះគឺដីតែមួយទេ គ្រាន់តែហៅពីមុនខុស។

- សាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនជាតំណាងមន្ទីរកសិកម្ម មានតួនាទីប្រធានមន្ទីរកសិកម្ម។ រឿងនេះកើតឡើងតាំងពីមុន តាំងពីមន្ទីរបរិស្ថាននៅកាន់កាប់ ក្រោយមក ក៏ប្រគល់មកឲ្យមន្ទីរកសិកម្ម។ រឿងនេះកើតឡើង ដោយសារតែគាត់ឈូសមិនឈប់ ទើបក្រុមហ៊ុនប្តឹងមក។ ការឈូសនោះ គឺបាត់ដីរបស់មន្ទីរកសិកម្មជាង១០០ហិចតា។ វិវាទនេះមិនមែនជារឿងធំនោះទេ គ្រាន់តែកុំឲ្យប្រជាជនបន្តឈូសឆាយទៀតទៅ។ ពួកគាត់ជាប្រជាពលរដ្ឋនៅភូមិឯន តែមករកអាស្រ័យផលនៅភូមិមានជ័យ។ ប្រជាពលរដ្ឋចូលអាស្រ័យផលហើយ តែខាងមន្ទីរស្នើសុំកុំឲ្យឈូសឆាយយកទៀត។ ដីដែលឈូសឆាយហើយ ខាងមន្ទីរនឹងពិចារណាគិតមើលទៀត អាចប្រគល់ជូនគាត់ ឬយ៉ាងណា អាស្រ័យលើរាជរដ្ឋាភិបាល។ ដីនោះចុងក្រោយនឹងធ្លាក់មកលើដីរដ្ឋវិញ។ ចំពោះ គោលការណ៍របស់រដ្ឋាភិបាល មុននឹងចេញ សជណ គឺបានកាត់ឆ្វៀលឲ្យប្រជាជនហើយ ទើបចេញផែនទីមក តែចេះមានការរំលោភយកបន្តទៀត ទើបមានបញ្ហាកើតឡើង។

<u>សវនាការលើកទី៣ (ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង៨ព្រឹក)</u>

- សាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនបានដឹងថា គេប្តឹងផ្តល់គ្នា។ ដីនោះជាដីរបស់ប្រជាជន មិនមែនដីរបស់ក្រុមហ៊ុនទេ។ ដីនោះ ខ្លួនបានចូលទៅធ្វើការកាន់កាប់ តាំងពីឆ្នាំ១៩៩២-១៩៩៣ ដោយដីរបស់ខ្លួននៅឆ្ងាយពីកន្លែងទំនាស់ប្រហែលកន្លះគីឡូដី។ ខ្លួនមិនដឹងរឿងគាត់ឲ្យត្រាក់ទ័រចូលឈូសឆាយដីក្រុមហ៊ុននោះទេ។ ខ្លួនបានឃើញដីនោះឈូសអស់ប្រហែល១ហិចតាជាង តែដីនោះនៅក្នុងដីរបស់ប្រជាពលរដ្ឋនោះទេ។ ដីនោះជាដីរបស់ឈ្មោះ [redacted]។ នៅពេលវាស់វែងនោះ គឺមានមេភូមិឯន មេឃុំឯន ចូលរួមដែរ។

- សាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនជាជនជាតិកួយ។ ខ្លួនដឹងថា ដីរបស់ឈ្មោះ [redacted] ជាប់នៅជាមួយដីខ្លួន មានព្រំប្រទល់ជាប់គ្នា តែមិនដឹងថាដីខ្លួនមានប៉ុន្មានហិចតានោះទេ ដោយប្រហែល៣ហិចតា។ សព្វថ្ងៃ ខ្លួននៅអាស្រ័យផលលើដីនោះដដែល។ ដីនោះនៅភូមិឯន មិនមែននៅភូមិមានជ័យនោះទេ។ ដីនោះខ្លួនធ្វើតែដីមួយកន្លែងនោះទេ។ ដីនោះ ឈ្មោះ [redacted] និងឈ្មោះ [redacted] ទៅភ្ជួរមែន។ ដីនោះនៅឆ្ងាយពីព្រំប្រទល់ក្រុមហ៊ុនប្រហែល១ហិចតា។ ការភ្ជួរនោះគឺនៅក្នុងដីរបស់ឈ្មោះ [redacted]។

- សាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនជាជនជាតិកួយ រកស៊ីដាំចន្ទីរ។ កាលពីមុន ខ្លួនធ្វើចំការជាលក្ខណៈវិលជុំ តែដោយសារក្រុមហ៊ុនឈប់ឲ្យធ្វើ ទើបធ្វើនៅតែដីមួយកន្លែងវិញ។ ខ្លួនដឹងថា ក្រុមហ៊ុនប្តឹងរឿងបំពានដីនោះដែលមានទំហំប្រហែល២០ហិចតា តែពេលចូលទៅវាស់មានតែ១ហិចតា១២អា។ ដីនោះនៅឆ្ងាយប្រហែល ២០០-៣០០ម៉ែត្រ ពីដីក្រុមហ៊ុន។ កន្លងមក ធ្លាប់មានការដោះស្រាយគ្នាម្តងរួចហើយនៅខេត្ត។

- សាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនដឹងថា ដីនោះជារបស់ឈ្មោះ [redacted]។ ដីខ្លួននៅក្បែរនោះដែរ។ ដីខ្លួនមានដាំដំឡូង ដោយនៅឆ្ងាយពីដីនោះប្រហែលកន្លះគីឡូម៉ែត្រ។

- សាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនដឹងអំពីរឿងដីឈ្មោះ [redacted] និងឈ្មោះ [redacted] នៅជាប់ព្រំប្រទល់ដីខ្លួន។ ដីនោះជាដីរបស់គាត់ មិនមែនដីរបស់ក្រុមហ៊ុននោះទេ។ ខ្លួនមិនដឹងថា ដីនោះគេកាត់ឆ្វៀល ឬអត់នោះទេ។

- សាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនរស់នៅតំបន់នោះ។ ខ្លួនស្គាល់ដីរបស់ឈ្មោះ [redacted] ច្បាស់ ដោយសារខ្លួនធ្លាប់ទិញផ្លែចន្ទីរពីគាត់រហូត។ ខ្លួនចូលបម្រើការនៅក្រុមហ៊ុនសម្បទានដីនោះនៅឆ្នាំ២០១៧ ធ្វើជាកម្មករជម្រះស្មៅ។ ឈ្មោះ [redacted] បានអាស្រ័យផលនៅលើដីនោះនៅឆ្នាំ២០១៤-២០១៥។ ខ្លួនស្គាល់ដីគាត់ ដោយដីគាត់នៅក្រៅរបងរបស់ក្រុមហ៊ុន។ ដីនោះមិនទាន់មានប្លង់រឹងនោះទេ។

- ក្រឡាបញ្ជីអានពាក្យស្នើសុំដកពាក្យបណ្តឹង ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] បានបញ្ជាក់ថា៖ ខ្លួនស្នើសុំដកពាក្យបណ្តឹង ដោយមូលហេតុនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ មានលិខិតស្នើសុំរបស់តំណាងប្រជាពលរដ្ឋចំនួន៥រូបក្នុងចំណោមប្រជាពលរដ្ឋ៥៩រូប ដែលស្ថិតនៅភូមិស្វាយ ភូមិរវៀង ភូមិឯន ភូមិ

វាលព្រីង ភូមិសំភី ភូមិក្រាំងដើម ភូមិអូរធ្លោត និងភូមិស្រឡៅ ឃុំឯន ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ស្នើសុំឱ្យពួកគាត់បានអាស្រ័យផលដំណាំចម្ការនៅក្នុងដីរបស់ក្រុមហ៊ុន សម្បត្តិ ផ្ទេធីណឹម ខូអិលធីឌី និងសន្យាមិនរុករានកាប់បំផ្លាញព្រៃឈើ ដើម្បីពង្រីកយកដីតទៅទៀត ដោយមានការសម្របសម្រួលពីអាជ្ញាធរភូមិ និងអាជ្ញាធរឃុំឯន និងមានភ្ជាប់ជាមួយស្នាមមេដៃឯកភាពពីប្រជាពលរដ្ឋផងដែរ។ ប៉ុន្តែ នៅមានប្រជាពលរដ្ឋមួយចំនួនផ្សេងទៀតដែលកំពុងអាស្រ័យផលដំណាំក្នុងក្រុមហ៊ុនដែរនោះពុំទាន់យល់ព្រមនៅឡើយ។ ម្យ៉ាងទៀត ពាក្យបណ្ដឹងខាងលើ ខ្លួនបាទក៏បានដាក់ពាក្យប្ដឹងមុនការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទើបចុះបញ្ជីរួចរាល់ផងដែរ។ ចំណែកឯផ្ទៃដីដែលពាក់ព័ន្ធនឹងប្រជាពលរដ្ឋ ត្រូវបានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត បានសម្រេចចិត្តកាត់ឆ្កៀលចេញ ដើម្បីទុកឱ្យប្រជាពលរដ្ឋអាស្រ័យផល និងធ្វើការដោះស្រាយនៅពេលក្រោយ។ ហេតុដូច្នេះ ខ្លួនបាទជាតំណាងក្រុមហ៊ុន សម្បត្តិ ផ្ទេធីណឹម ខូអិលធីឌី ឈប់ទាមទារសំណង ឬទាមទារអ្វីផ្សេងៗតទៅទៀតហើយ។

**- ភស្តុតាងបានលើកយកមកសំអាងក្នុងសវនាការ៖**

១-លិខិតលេខ៖៩៣៥ សជណ.កស ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

២-ផែនទីទីតាំងដីវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ របស់ក្រុមហ៊ុន សម្បត្តិ ផ្ទាទីណឹម ខូអិលធីឌី ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។

៣-អនុក្រឹត្យលេខ៖២៣៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការធ្វើអនុបយោគផ្ទៃដីទំហំ ២.៤៩០ហិចតា ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតក្នុងភូមិសាស្ត្រឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។

៤-កំណត់ហេតុស្ដីពីការចុះរុករកការលួចឈូសឆាយដីព្រៃក្រុមហ៊ុន សម្បត្តិ ផ្ទាទីណឹម ខូអិលធីឌី នៅក្នុងឃុំឯន ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។

៥-លិខិតស្នើសុំជួយអន្តរាគមន៍ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២១ របស់ក្រុមហ៊ុន សម្បត្តិ ផ្ទេធីណឹម ខូអិលធីឌី។

៦-របាយការណ៍ស្ដីពីការចុះពិនិត្យការប្ដឹងជំទាស់របស់តំណាងសហគមន៍ជនជាតិដើមភាគតិច(កួយ) ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រុមការងារចុះបញ្ជីដីរដ្ឋថ្នាក់ខេត្ត។

៧-បញ្ជីវត្តមានស្ដីពីការចុះបញ្ជីដីរវាងសហគមន៍ក្បិតចង្កូរខ្នារ និងសហគមន៍ជនជាតិដើមភាគតិច(កួយ) ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រុមការងារចុះបញ្ជីដីរដ្ឋថ្នាក់ខេត្ត។

៨-កំណត់ហេតុស្ដីពីការរកដំណោះស្រាយបញ្ហានៃពាក្យបណ្ដឹងរបស់ប្រជាជននៃជនជាតិដើមភាគតិចភូមិចង្កូរខ្នារ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤ របស់សាលាស្រុកសណ្ដាន់។

៩-កំណត់ហេតុស្ដីពីការចុះពិនិត្យ និងវាស់វែងដីប៉ះពាល់របស់ប្រជាពលរដ្ឋក្នុងក្រុមហ៊ុនសម្បត្តិផ្ទាទីនីម ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ឃុំឯន (ភ្ជាប់ជាមួយបញ្ជីវត្តមាន)។

១០-លិខិតលេខ៖១១៤៦ សជណ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ។

១១-លិខិតលេខ៖១១៦៥/១៦ កអជ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

១២-ពាក្យស្នើសុំបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted]ប។

១៣-លិខិតលេខ៖២៤៧៩/២០ សជណ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ របស់រដ្ឋបាលខេត្តកំពង់ធំ។

១៤-របាយការណ៍ស្ដីពីការប្រជុំពិនិត្យទីតាំងកំណត់ព្រំប្រទល់ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ របស់អភិបាលរងខេត្តកំពង់ធំ។

១៥-លិខិតស្នើសុំ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ របស់ប្រជាពលរដ្ឋក្នុងភូមិស្វាយ ភូមិងន ភូមិរាលព្រីង ភូមិសំភី និងភូមិស្រឡៅ ឃុំងន ស្រុកសណ្ដាន់ ខេត្តកំពង់ធំ និងបញ្ជីវត្តមាន។

១៦-សេចក្ដីសម្រេចលេខ៖២៧២/១៧ សសរ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ របស់មេឃុំងន។

១៧-លិខិតបញ្ជាក់លេខ៖២៧១/២២ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ របស់រដ្ឋបាលឃុំងន។

១៨-កំណត់ហេតុស្ដីពីការចុះផ្ទៀងផ្ទាត់ទំហំដីអាស្រ័យផលបណ្ដោះអាសន្ន ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣ របស់ឃុំងន (ភ្ជាប់ជាមួយបញ្ជីវត្តមាន)។

១៩-លិខិតបញ្ជាក់លេខ៖៥៧៨/២៣ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣ របស់រដ្ឋបាលឃុំងន។

២០-លិខិតបញ្ជាក់លេខ៖៤២៥/២២ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ របស់រដ្ឋបាលឃុំងន។

២១-ពាក្យសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ របស់ឈ្មោះ[redacted]។

២២-សេចក្ដីប្រកាសស្វ័យអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចកួយ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ របស់ឈ្មោ[redacted]។

២៣-លក្ខន្តិកៈក្រុមហ៊ុន សម្បត្តិ ផ្ទៃទឹណឹម ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១ របស់ឈ្មោះ[redacted]។

២៤-របាយការណ៍វឌ្ឍនភាពស្ដីពីលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចប្រចាំឆ្នាំ២០២១ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ របស់ឈ្មោះ[redacted]។

២៥-ព្រឹត្តិប័ត្រពត៌មានក្រុមហ៊ុន សម្បត្តិ ផ្ទៃទឹណឹម ខូអិលធីឌី ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ របស់ឈ្មោះ [redacted]។

២៦-កិច្ចសន្យាស្ដីពីការចូលដាំដំឡូងមីក្នុងទីតាំងក្រុមហ៊ុន សម្បត្តិ ផ្ទៃទឹណឹម ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១ របស់ឈ្មោះ[redacted]និងឈ្មោះ[redacted]។

២៧-ប្លង់បង្ហាញទីតាំងដីជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន សម្បត្តិ ផ្ទាទឹណឹម ខូអិលធីឌី ស្ថិតនៅក្នុងភូមិជាន់លែង និងភូមិថ្មី ឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។

២៨-រូបថត។

- គ្មានវត្ថុដែលចាប់យក ដែលត្រូវធ្វើការសម្រេចពីការរឹបអូស ឬប្រគល់ឲ្យម្ចាស់ដើមវិញក្នុងសំណុំរឿងនេះទេ ហេតុដូច្នេះ តុលាការមិនលើកមកពិចារណាឡើយ។

- តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា៖ ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ ចម្លើយបណ្ដាសាក្សី មន្ត្រីជំនាញ និងពិនិត្យភស្តុតាងនានា ឃើញថា ឆ្លងកាត់សវនាការចំនួនបីលើករួចមក ឃើញថា ដីនោះបើក្រុមហ៊ុនអាចទាមទារមកវិញបានមែនក៏ដោយ ក៏ចុងក្រោយដីនោះត្រូវធ្លាក់ទៅលើដីរបស់រដ្ឋវិញដែរ។ម្យ៉ាងទៀត ដើមបណ្ដឹងក៏បានដកពាក្យបណ្ដឹងវិញ ដោយស្នើសុំកុំឲ្យកាប់រានតទៀត។ មន្ត្រីជំនាញបានបញ្ជាក់ថា ដីវិវាទនោះគឺស្ថិតនៅភូមិមានជ័យ ឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ហេតុដូច្នេះ តំណាងអយ្យការស្នើសុំផ្លាស់ប្ដូរទីកន្លែងប្រព្រឹត្តទៅជាភូមិមានជ័យ ឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ វិញ និងសុំឲ្យតុលាការសម្រេចតាមច្បាប់ ប៉ុន្តែ អាចសម្រាលទោសឲ្យជនជាប់ចោទ។

- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ[redacted] និងឈ្មោះ [redacted] មេធាវី [redacted] ធ្វើសេចក្ដីសន្និដ្ឋានការពារ៖ ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ឃើញថា មិនមានបទល្មើសប្រើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិតនោះទេ តាមមាត្រា២៥៣ នៃច្បាប់ភូមិបាល នោះទេ។ ដើមបណ្ដឹងជាក្រុមហ៊ុនបានទទួលសិទ្ធិសម្បទានដីពីរដ្ឋាភិបាលតាមកិច្ចព្រមព្រៀង ដូច្នេះ គាត់មិនមែនជាកម្មសិទ្ធិករនោះទេ ហើយសម្បទានដីក៏មិនអាចក្លាយជាកម្មសិទ្ធិនោះទេ។ គាត់មិនមែនជាអ្នកកាន់កាប់ដីដោយសុច្ចរិត

នោះទេ ស្របតាមមាត្រា៣៨ នៃច្បាប់ភូមិបាលទេ។ ដូច្នេះ មិនមានធាតុផ្សំជាបទល្មើស ប្រើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត តាមមាត្រា២៥៣ នៃច្បាប់ភូមិបាល នោះទេ។ម្យ៉ាងទៀត ទំហំដីដែលជាកម្មវត្ថុនៃវិវាទ ក៏មិនស៊ីសង្វាក់គ្នារវាងឯកសារប្តឹងថា២១ហិកតា ចំណែកដីជាក់ស្តែង ដែលកូនក្តីខ្លួនឲ្យកូនរបស់គាត់ភ្ជួរមានតែទំហំ ១ហិកតា៣៤អា។ ដូច្នេះ សូមតុលាការសម្រេចឲ្យកូនក្តីឈ្មោះ [redacted] និងឈ្មោះ [redacted] រួចផុតពីបទចោទប្រកាន់របស់តំណាងអយ្យការ ដើម្បីផ្តល់យុត្តិធម៌ដល់អ្នកទាំងពីរ។

- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] មេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានការពារ៖ ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ឃើញថា ខ្លួនសុំឯកភាពតាមការសន្និដ្ឋានរបស់សហភាគាលោកមេធាវី [redacted]។ ជាក់ស្តែង នៅពេលពួកគាត់ចុះវាស់វែងផ្ទាល់បានអះអាងថា ដីវិវាទនោះនៅភូមិមានជ័យ ប៉ុន្តែ តាមការបញ្ជាក់របស់មេភូមិ បានអះអាងថាដីវិវាទនោះនៅភូមិឯនទេ។ ទីតាំងដីវិវាទជាដីរបស់លោក [redacted]។ ដើមបណ្តឹងបានអះអាងថា ដីរបស់គាត់ដែលប្រជាជនឈូសឆាយមានទំហំ២០ហិចតាជាង ប៉ុន្តែពេលវាស់ជាក់ស្តែងគឺមានតែ១ហិចតាជាងទេ។ ដូច្នេះ មិនមានមូលហេតុច្បាស់លាស់នោះទេ ដែលបង្ហាញថា ការចោទប្រកាន់គឺមានវិមតិសង្ស័យ ដែលត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ដូច្នេះ សំណូមពរស្នើសុំឲ្យតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] មេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានការពារ៖ ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ឃើញថា ខ្លួនសូមឯកភាពតាមការសន្និដ្ឋានការពាររបស់សហភាគាដែលបានសន្និដ្ឋានការពារ។ វិវាទក្នុងសំណុំរឿងនេះជាវិវាទដីធ្លី ហើយក្រុមហ៊ុនមិនបានសិក្សាពីទីតាំងដីដែលបានរងការឈូសឆាយនោះទេ ដោយបានអះអាងថាមានប្រហែល ២០ហិចតា តែឈូសឆាយតែ ១ហិចតាទេ។ កូនក្តីមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ ដូច្នេះ សំណូមពរស្នើសុំឲ្យតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

- សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] សំណូមពរតុលាការទម្លាក់ចោលការចោទប្រកាន់លើខ្លួន។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់ចម្លើយអាជ្ញាធរ
- ក្រោយពីបានស្តាប់ចម្លើយបណ្តាសាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានតំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

## ៣.សំអាងហេតុ

**ក្រោយពីបានពិចារណាលើសេចក្តីសន្និដ្ឋានរបស់ភាគី ភស្តុតាង និងឯកសារនានាក្នុងសំណុំរឿង**

**សាលាដំបូងខេត្តកំពង់ធំ៖**

១. យល់ឃើញថា៖ តុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ៥៣ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ២៤ឆ្នាំ (សាវតាជាតិខាងលើ) ដែលបានប្រព្រឹត្តអំពើដែលបណ្តាលឲ្យមានព្យសនកម្មកើតឡើង កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ នៅចំណុចតំបន់ក្បិតបង្គួរខ្មា ភូមិឯន ឃុំឯន ស្រុកសណ្តាន់ ខេត្តកំពង់ធំ ត្រូវបានជាប់ចោទពីបទៈ ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត តាមមាត្រា២៥៣ នៃច្បាប់ភូមិបាល។

២. យល់ឃើញថា: ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនបានឈូសឆាយនៅលើដីចម្ការចន្ទីរបស់ឈ្មោះ [redacted] តែខ្លួនមិនបានឈូសឆាយដីរបស់ក្រុមហ៊ុននោះទេ ព្រោះដីនោះជាដីរបស់ឈ្មោះ [redacted] ទេ ដោយសារខ្លួនបានដីនោះពីឈ្មោះ [redacted] ខ្លួនបានឈូសឆាយក្នុងគោលបំណង ដើម្បីដាំដំឡូងទេ ហើយព្រៃដែលឈូសនោះ គឺមិនមានព្រៃធំដុំនោះទេ។ ពេលដែលខ្លួនឈូសដីនោះ គឺមានទំហំ១ហិចតា៣៤អា ដោយទើបតែឈូសបាន១ថ្ងៃជាងទេ ក៏មានការមកឃាត់ត្រាក់ទ័រ ហើយឈូសបានតែប៉ុននេះទេ។ កាលពីឆ្នាំ២០១២ ដីនោះគឺជាដីរបស់ក្រុមហ៊ុនមែន។ រីឯ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ មកដល់បច្ចុប្បន្ននេះ ដីនោះបានប្រគល់ឱ្យទៅឈ្មោះ [redacted] វិញហើយ។ ខ្លួនបានឈូសឆាយលើដីនោះបានតែទំហំ ១ហិចតា៣៤អា ទេ។ ខ្លួនមិនដែលបានជជែកដោះស្រាយជាមួយក្រុមហ៊ុននោះទេ។ ចំពោះ ត្រាក់ទ័រនោះ គឺទិញយកមកដើម្បីឱ្យគេជួល ហើយអ្នកបើកជាកម្មករខ្លួន ដែលខ្លួនជួលឱ្យឈូសដីនោះ។

ដូច្នេះ ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទទាំងពីរនាក់ខាងលើនេះមានភាពស៊ីសង្វាក់ជាមួយចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចម្លើយបណ្តាសាក្សី ព្រមទាំងភស្តុតាងនានា ដែលបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] និងជនជាប់ចោទឈ្មោះ [redacted] ពិតជាបានធ្វើការឈូសឆាយចូលលើដីដែលក្រុមហ៊ុន សម្បត្តិ ផ្តេធីណឹម ខូអិលធីឌី បានទទួលសម្បទានពិតប្រាកដមែន។ តាមចម្លើយបណ្តាសាក្សីឈ្មោះ [redacted] ជាអ្នកចុចជីភីអេស (GPS) និងឈ្មោះ [redacted] ជាប្រធានមន្ទីរកសិកម្ម ព្រមទាំងភស្តុតាងនានាជាផែនទីបង្ហាញទីតាំងដីវិវាទ ដែលបញ្ជាក់ថា ទីតាំងដីកើតហេតុនេះ គឺស្ថិតនៅក្នុងផែនទីរបស់ក្រុមហ៊ុនសម្បទានដី សម្បត្តិ ផ្តេធីណឹម ខូអិលធីឌី មែន។ ហេតុដូច្នេះ ជនជាប់ចោទឈ្មោះ [redacted] និងជនជាប់ចោទឈ្មោះ [redacted] ពិតជាបានធ្វើការឈូសឆាយចូលដីរបស់ក្រុមហ៊ុន សម្បត្តិ ផ្តេធីណឹម ខូអិលធីឌី នៅមុនការកាត់ឈ្មៀល ដែលកំពុងស្ថិតក្រោមការកាន់កាប់របស់ក្រុមហ៊ុនដែលបានទទួលសម្បទានស្របច្បាប់ពីរដ្ឋ ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ ប្រាកដមែន ដូច្នេះ អំពើរបស់ជនជាប់ចោទខាងលើ ជាអំពើខុសច្បាប់ ស្របតាមស្មារតីនៃមាត្រា២៥៣ នៃច្បាប់ភូមិបាល។

ដោយឡែកចំពោះចម្លើយរបស់ជនជាប់ចោទ និងចម្លើយសាក្សីផ្សេងៗទៀត ដែលបានឆ្លើយបំភ្លឺដោះបន្ទុកថា៖ ដីទំនាស់នោះមិនស្ថិតនៅក្នុងដីរបស់ក្រុមហ៊ុន គឺមិនស្របគ្នាឡើយ ហាក់ដូចមិនអាចឱ្យតុលាការជឿបានឡើយ ដោយហេតុថា ជនជាប់ចោទធ្លាប់ទទួលស្គាល់ថាជាដីរបស់ក្រុមហ៊ុន និងមានចម្លើយរបស់សាក្សីមួយចំនួនឆ្លើយផ្ទុយគ្នា មិនស៊ីសង្វាក់គ្នាទៅចម្លើយរបស់អ្នកជំនាញ និងអាជ្ញាធរមូលដ្ឋាន ព្រមទាំងភស្តុតាងផ្សេងៗ ដែលមានដាក់ជូនតុលាការ។ សេចក្តីសន្និដ្ឋានការពាររបស់សហមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទថា កូនក្តីខ្លួនពុំបានប្រព្រឹត្តអំពើល្មើសដូចចែងក្នុងមាត្រា២៥៣ នៃច្បាប់ភូមិបាល គឺជាការយល់ឃើញមិនស្របនឹងស្មារតីច្បាប់ដែលបានចែងក្នុងមាត្រាខាងលើឡើយ ហេតុនេះ គប្បីតុលាការពិនិត្យពិចារណាឱ្យច្បាស់លាស់លើចំណុចទាំងអស់នេះ ដោយប្រកាន់ខ្ជាប់នូវការអនុវត្តច្បាប់ជាធរមាន។

៣.យល់ឃើញថា: តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ៖ តម្កល់ការចោទប្រកាន់ និងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមផ្លូវច្បាប់។ ចំពោះ សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ មានភាពជឿជាក់បានថា អំពើរបស់ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ ហេតុដូច្នេះ គប្បីតុលាការពិចារណា។

៤. យល់ឃើញថា: មេធាវីការពារឱ្យជនជាប់ចោទ មេធាវី [redacted], មេធាវី [redacted] និងមេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានការពារថា៖ សុំឱ្យតុលាការធ្វើសម្រេចឱ្យកូនក្តីខ្លួនរួចពីបទចោទ។ ដូចបានលើកទឡ្ហីករណ៍ខាងលើរួចហើយថា អំពើរបស់ជនជាប់ចោទមានចេតនា និងធាតុផ្សំបទល្មើសគ្រប់គ្រាន់ ដែលអាចផ្តន្ទាទោសបាន។ ហេតុដូច្នេះ គប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

៥៩/២

៥. យល់ឃើញថា៖ មានពិរុទ្ធភាព និងមានភស្តុតាងនានាគ្រប់គ្រាន់ បានធ្វើឱ្យតុលាការជឿជាក់បានថា អង្គហេតុខាងលើនេះ ជនជាប់ចោទឈ្មោះ [redacted] និងជនជាប់ចោទឈ្មោះ [redacted] ពិតជាបានធ្វើការឈូសឆាយចូលដីរបស់ក្រុមហ៊ុន **សម្បត្តិ ផ្លេធីណឹម ខូអិលធីឌី** នៅមុនការកាត់ឆ្វៀល ដែលកំពុងស្ថិតក្រោមការកាន់កាប់របស់ក្រុមហ៊ុនដែលបានទទួលសម្បទានស្របច្បាប់ពីរដ្ឋ ដែលត្រូវជាប់ចោទពីបទ៖ ប្រើ **អំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ តាមមាត្រា២៥៣ នៃច្បាប់ភូមិបាល ដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.៥០០.០០០(មួយលានប្រាំសែន)រៀល ទៅ ២៥.០០០.០០០(ម្ភៃប្រាំលាន)រៀល ឬ/និងដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ទៅ ២(ពីរ)ឆ្នាំ។

៦. យល់ឃើញថា៖ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] និងជនជាប់ចោទឈ្មោះ [redacted] ដែលធ្វើសកម្មភាពខាងលើ បានស្តែងចេញមកខាងក្រៅ ហើយក៏មានចេតនាក្នុងការប្រព្រឹត្ត ដោយអំពើនេះ វាធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ និងខុសច្បាប់រដ្ឋជាធរមាន តុលាការសម្រេចពីការផ្តន្ទាទោសតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌតាមមាត្រា៤ និងមាត្រា៩៦ នៃក្រមព្រហ្មទណ្ឌ។

៧. យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] និងជនជាប់ចោទឈ្មោះ [redacted] បានចូលរួមសហការ និងឆ្លើយសហការណ៍ល្អជាមួយតុលាការគ្រប់ដំណាក់កាលនីតិវិធី។ ម្យ៉ាងទៀត ដីដែលជាទីតាំងនៃបទល្មើសនេះត្រូវបានកាត់ឆ្វៀលតាមនីតិវិធីរួចហើយទៀត។ ហេតុដូច្នេះ ផ្អែកតាមកាលៈទេសៈនៃការប្រព្រឹត្ត បុគ្គលិកលក្ខណៈ សភាពផ្លូវចិត្ត ធនធាន និងបន្ទុកគ្រួសារ និងកិរិយាមាយាទក្រោយប្រព្រឹត្តរបស់ជនជាប់ចោទ តុលាការសម្រេចពីការប្រកាសទោសព្យួរ តាមមាត្រា១០៦ មាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ។

៨. យល់ឃើញថា៖ ជនជាប់ចោទមានពិរុទ្ធភាពក្នុងអំពើដែលបានប្រព្រឹត្ត ដូច្នេះ ជនជាប់ចោទត្រូវទទួលខុសត្រូវសំណងផ្នែករដ្ឋប្បវេណីចំពោះអំពើអំប្រព្រឹត្តរបស់ខ្លួន។ ប៉ុន្តែ ដើមបណ្តឹងរដ្ឋប្បវេណី បានដកពាក្យបណ្តឹង មិនទាមទារសំណងជុសជុលការខូចខាតចំពោះអំពើរបស់ជនជាប់ចោទនេះតទៀត ហេតុដូច្នេះ តុលាការមិនលើកមកធ្វើការសម្រេចសេចក្តីឡើយ។

៩. យល់ឃើញថា៖ គ្មានវត្ថុដែលចាប់យក ដែលត្រូវធ្វើការសម្រេចពីការរឹបអូស ឬប្រគល់ឱ្យម្ចាស់ដើមវិញក្នុងសំណុំរឿងនេះទេ ហេតុដូច្នេះ តុលាការមិនលើកយកមកធ្វើការសម្រេចនោះឡើយ។

## ៤.សេចក្តីសម្រេច

**តាមសំអាងហេតុ និងក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**សាលាដំបូងខេត្តកំពង់ធំសម្រេច ÷**

**ផ្តន្ទាទោសលើ៖**

១. ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ៥៣ឆ្នាំ ដាក់ពន្ធនាគារម្នាក់ៗកំណត់ ១(មួយ)ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសដែលជាប់ពន្ធនាគាររួច ចំពោះ ទោសនៅសល់អនុវត្តត្រូវព្យួរទោសធម្មតា

២. ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ២៤ឆ្នាំ ដាក់ពន្ធនាគារម្នាក់ៗកំណត់ ១(មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរទោសធម្មតា

ជាប់ចោទពីបទ៖ **ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត** ប្រព្រឹត្តនៅចំណុចភូមិថ្មី ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ តាមមាត្រា២៥៣ នៃច្បាប់ភូមិបាល។

សាលក្រមនេះបានធ្វើការជំនុំជម្រះនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ និងបានប្រកាសជាសាធារណៈថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ ចំពោះមុខឈ្មោ[redacted] និងឈ្មោះ[redacted]។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។

ថ្ងៃអង្គារ ៩កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកំពង់ធំ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]